**Discretion to Prosecute (pp. 135-141) Colin Wells, Abuse of Process, 2006**

**១.** បទល្មើសព្រហ្មទណ្ឌ ដែលមានទោសដាក់ក្នុងពន្ធនាគារ ត្រូវបានរាយការណ៍ ឬមិនត្រូវបានដឹង។ ប្រសិនបើអាជ្ញាធរបានដឹងទាំងអស់ និងរងការចោទប្រកាន់ទាំងអស់នោះ វាទំនងជារដ្ឋត្រូវតែបង្កើតពន្ធនាគារជាច្រើន។ អាស្រ័យហេតុនេះ ច្បាប់និងការអនុវត្ត បានអនុញ្ញាតឱ្យមានភាពបត់បែន។ ឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ ត្រូវបានប្រកាន់យក ដែលតម្រូវឱ្យរដ្ឋអាជ្ញា ពិចារណាលើកត្តាជាច្រើន។ តុលាការមានភាពស្ទាក់ស្ទើរ ក្នុងការពិនិត្យការអនុវត្តឆន្ទានុសិទ្ធិក្នុងការចោទប្រកាន់ ឬមិនចោទនេះ។

**២.** កត្តាទាំងនោះវាផ្អែកលើគោលនយោបាយ ឬថាតើមានភស្តុតាងគ្រប់គ្រាន់ ឬមិនមានសម្រាប់ការចោទប្រកាន់។ ជួនកាលជំនួសឱ្យការចោទប្រកាន់ អាជ្ញាធរប្រើវិធានការ caution (ព្រមាន) ដែលបង្ហាញការព្រមព្រៀងគ្នាផងដែរ រវាងនគរបាលនិងជនជាប់ចោទ។ Caution ស្ថិតនៅក្រោមការពិនិត្យរបស់រដ្ឋអាជ្ញា។ ការសម្រេចចោទឬមិនចោទ ត្រូវពិចារណាផងដែរនូវផលប្រយោជន៍របស់ជនរងគ្រោះ តាមរយៈការពិគ្រោះ (victim consultation)។ ទោះបីជាយ៉ាងនេះក្តី ការសម្រេចមិនចោទ មិនអាចហាមនូវការចោទប្រកាន់ជាឯកជនទេ (private prosecution) ដែលអនុវត្តក្នុងប្រទេសមួយចំនួន។

**៣.** ពាក់ព័ន្ធនឹងការសម្រេចចោទឬមិនចោទនេះដែរ អាជ្ញាធរក៏ត្រូវពិចារណាផងដែរ អំពីជម្រើសនៃការចោទ (បទល្មើសស្រាលឬបទល្មើសធ្ងន់) និងការចែករំលែកទោសរវាងសហចារី សមត្ថកិច្ចនៃស្ថាប័នដទៃអាចធ្វើការចោទប្រកាន់បាន (ទុកឱ្យអាជ្ញាធរនោះចាត់វិធានការចុះ)។ ជាចុងក្រោយ គេត្រូវពិចារណាថា តើអាជ្ញាយុកាលនៃការចោទប្រកាន់នៅមានទេ (statute of limitation)?